## ៦. ផែនការគ្រប់គ្រងបរិស្ថាន-តម្រូវការស្ថាប័ន និងការពិនិត្យ-តាមដាន-វាយតំលៃបរិស្ថាន

**២២៧.** យោងលើកំរិតនៃផលប៉ះពាល់បង្កឡើងដោយសកម្មភាពអភិវឌ្ឍន៍បង្ហាញថា គំរោងនេះមិនតម្រូវឱ្យមានការចូលរួមពីស្ថាប័ន និងការត្រួតពិនិត្យបរិស្ថានច្រើនប៉ុន្មានទេ ដោយសារថា ហេតុប៉ះពាល់អវិជ្ជមានមានតិចតួច។ ក្រៅពីអ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator) និងស្ថាប័នជំនាញ (មានក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) គម្រោងនេះមិនចាំបាច់តម្រូវឱ្យមានស្ថាប័នត្រួតពិនិត្យឯករាជ្យ (Independent Monitoring Organization) ដើម្បីត្រួតពិនិត្យការអនុវត្តន៍ទេ។ ប៉ុន្តែក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** ខ្លួនឯងមានតួនាទីទទួលខុសត្រូវស្នូលក្នុងការគ្រប់គ្រងបរិស្ថាន របស់គំរោង ដោយផ្អែកលើវិធានការណ៍គ្រប់គ្រងបរិស្ថានដូចបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន របស់របាយការណ៍ ESIA។ ក្នុងបរិបទនេះ ដើម្បីធានាបានថា ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** ប្រតិបត្តិតាមវិធានការណ៍ នៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម ដូចកំណត់នៅក្នុងតារាង ទី ៦-១ និង ៦-៣ បានត្រឹមត្រូវនោះ ក្រសួងបរិស្ថាន និងក្រុមការងារអន្តរក្រសួង ត្រូវចុះពិនិត្យ និងវាយ តំលៃដំណើរប្រតិបត្តិការរបស់ក្រុមហ៊ុន ទៅតាមកម្មវិធីដូចមានកំណត់នៅក្នុងតារាង ៦-៣ ដោយផ្ទាល់។

Draft

### តារាង ៦-១ : វិធានការសង្ខេបកាត់បន្ថយហេតុប៉ះពាល់

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងសុវត្ថភាពការងារ និងសុខភាពបុគ្គលិកម្មករ** | | | | |
| ការរៀបចំគំរោង | រៀបចំគំរោងមិនបានត្រឹមត្រូវ (ប្រសិនបើ) | • ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** បានប្រើទស្សនៈ នៃការអភិវឌ្ឍន៍ លក្ខណៈជាប្រព័ន្ធក្នុងការរៀបចំគំរោង ដោយមានការបែងចែកការ ប្រើប្រាស់ដីសំខាន់១ពីរ ប្រភេទគឺ :<br>១. ដីប្រើប្រាស់: ដីសម្រាប់ដាំកៅស៊ូ និងដីសម្រាប់រៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ។<br>២. ដីដែលមិនអាចប្រើប្រាស់បាន: និងដីតំបន់ទ្រនាប់ ប្រព័ន្ធផ្លូវទឹក ដែលត្រូវកាត់ចេញដូចបញ្ជាក់នៅត្រង់ចំណុច ឧបសម្ព័ន្ធ ៣-១ របាយការណ៍ស្តីពីលទ្ធផលនៃការចុះសិក្សាទីតាំងស្នើសុំដីសម្បទាន។<br>• ត្រូវសហការជាមួយក្រុមការងារអន្តរក្រសួងរួមមាន : ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរមូលដ្ឋាន ធ្វើការត្រួតពិនិត្យ និងវាយតំលៃដង់ស៊ីតេឈើ និងមាឌឈើឈរទៅតាមការជាក់ស្តែង ដែលមាននៅក្នុងតំបន់ដីសម្បទាន ដើម្បីបង់ចូលថវិការជាតិ។<br>• ត្រូវរៀបចំផែនការមូលនិធិបរិស្ថាន ដើម្បីរៀបចំផែនការដាំដើមឈើឡើងវិញ នៅក្នុងតំបន់វិនិយោគ។ | ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | តាមជាក់ស្តែង |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ពន្ធ័នឹងសុវត្ថភាពការងារ និងសុខភាពបុគ្គលិកម្មករ (ត)** | | | | |
| ការធ្វើផែនការ | សុខភាពការងារ និងផែនការសុវត្ថិភាព | **(១) ការការពារជំងឺគ្រុនចាញ់ :** ប្រសិនបើគ្មានការគ្រប់គ្រងកន្លែងដែលមូសរស់នៅឱ្យបានជិតដល់ទេ អាចនឹងធ្វើឱ្យកើតជំងឺគ្រុនចាញ់បាន។ អនុសាសន៍សំខាន់ៗសំរាប់ការការពារនិងការ កាត់បន្ថយនូវការកើតជំងឺមានដូចជា: (១) ការស្វែងរកឱ្យបានទាន់ពេលវេលាតាមរយៈការពិនិត្យលើលក្ខណៈ គ្លីនិកចំពោះអ្នកផ្ទុកជំងឺដែលមានលក្ខណៈខ្ពស់ (២) ផ្តល់ការព្យាបាលឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់នៅគ្រប់ករណីនៃការកើតមានទាំងអស់ (៣) ធ្វើរបាយការណ៍អំពីការកើតមាននិងតាមដានអ្នកដែលប៉ះពាល់ឬនៅជាមួយនឹងអ្នកជំងឺ (៤) ផ្តល់ការណែនាំអំពីការប្រើថ្នាំការពារជំងឺគ្រុនចាញ់ឱ្យបានត្រឹមត្រូវ (៥) ជ្រលក់មុងជាមួយនឹងរបាយ Pyrathroid (៦) អនុវត្តន៍ គំរោងកែលំអអនាម័យ ដើម្បីបំបាត់កន្លែងរស់នៅរបស់មូស និងផ្តល់ការអប់រំអំពីបញ្ហាសុខភាព និងការការពារជំងឺគ្រុនចាញ់ (៧) ដាក់សំណាញ់តាមទ្វារ និងបង្អួចផ្ទះ (៨) ប្រើមុងជាប្រចាំ (៩) ស្លៀកពាក់ខោអាវដៃវែងនិងប្រើថ្នាំការពារមូស (១០) តាមដានគ្លីនិកនិងរោគសញ្ញារបស់ជំងឺ (១១) ធ្វើរោគវិនិច្ឆ័យនិងផ្តល់ការព្យាបាលឱ្យបានទាន់វេលា និង (១២) ត្រួតពិនិត្យនូវឧប្បត្តិហេតុ និងកំណត់ទីកន្លែងកើតមានជំងឺ។<br>**(២) ការគ្រប់គ្រងការរាគត្បាត:** វិធានការគ្រប់គ្រងការរាគត្បាតមាន (១) បំបែកអ្នកជំងឺឱ្យនៅផ្សេង និងព្យាបាលទៅតាមប្រភេទជំងឺ (២) បាញ់ថ្នាំក្នុងបរិវេណរស់នៅ២០០ម៉ែត្រ ដើម្បីសម្លាប់មូសដែលពេញវ័យ (៣) ស្វែងរក និងបំផ្លាញជំរកមូស (៤) ប្រើប្រាស់ថ្នាំសំលាប់ពងមូសតាមកន្លែងមានមូសច្រើន និង (៥) អប់រំបុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការគ្រប់គ្រងការរាគត្បាត។ | ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងសុវត្ថភាពការងារ និងសុខភាពបុគ្គលិកម្មករ (ត)** | | | | |
| ការធ្វើផែនការ | សុខភាពការងារ និងផែនការសុវត្ថិភាព | (៣) **ការការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាត:** ការកើតជំងឺគ្រុនពោះវៀន រាគមូល អាសន្នរោគ រលាកថ្លើម និងទឹកស៊ីជើងមានកំរិតខ្ពស់ ដោយសារការខ្វះអនាម័យ ការប្រើប្រាស់បង្គន់សាធារណៈមានកំរិតទាប ការផ្គត់ផ្គង់ទឹកស្អាតនៅមានកំរិត និងការខ្វះអនាម័យរបស់កម្មករ។ អនុសាសន៍មួយចំនួនដែលអនុវត្តសម្រាប់ការពារនូវការកើតនូវជំងឺខាងលើមាន: (ក) ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ (ខ) ត្រួតពិនិត្យជាប្រចាំអំពីគុណភាពរបស់ទឹក (វត្តមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក) (គ) ត្រូវធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា (ឃ) តាមដានរកប្រភពចំលងនិងផ្តល់ការព្យាបាល (ង) ធានាឱ្យបាននូវសុវត្ថិភាព និងអនាម័យកាកសំណល់ និងការបោះចោលនូវកាកសំណល់រឹងនៅក្នុងផ្ទះដែលសង់សំរាប់កម្មករ (ច) កែលំអការសម្អាតបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងទីកន្លែងរស់នៅ ដោយការសង់បង្គន់អនាម័យ និងកន្លែងចោលកាកសំណល់រឹង (ឆ) កែលំអអនាម័យបុគ្គល ជាពិសេសចំពោះអ្នករៀបចំអាហារ (ជ) ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទីករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម និង (ឈ) រាយការណ៍និងធ្វើការត្រួតពិនិត្យអំពីឧប្បត្តិហេតុរបស់ជំងឺ។ | ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងសុវត្ថភាពការងារ និងសុខភាពបុគ្គលិកម្មករ (ត)** | | | | |
| ការធ្វើផែនការ | សុខភាពការងារ និងផែនការសុវត្ថិភាព | (៤) **ការការពារជំងឺផ្លូវភេទ:** ការការពារជំងឺផ្លូវភេទចំពោះកម្មករ និងសហគមន៍មូលដ្ឋាន អាចធ្វើបានតាមរយៈ (ក) អប់រំបុគ្គលិកកម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀតដូចជា: ការទប់ស្កាត់នូវទំនាក់ទំនងជាមួយអ្នកដែលធ្វើអាជីវកម្មផ្លូវភេទការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺឱ្យព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានបទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង និង (ខ) រាយការណ៍អំពីអ្នកជំងឺ ស្វែងរកអ្នកចម្លង និងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាង អាជ្ញាសុខាភិបាល អាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។<br>(៥) **ការរៀបចំផ្ទះ និងសុខភាព:** ការរៀបចំផ្ទះមិនបានត្រឹមត្រូវ អាចនាំឱ្យមានការចម្លងប៉ារ៉ាស៊ីតជំងឺចំលងតាមខ្យល់ គ្រោះថ្នាក់ដោយការប៉ះទង្គិច និងស្រេសជាដើម។ តែបញ្ហាទាំងនេះអាចកាត់បន្ថយតាមរយៈការអនុវត្តនីវិធានការមួយចំនួនដូចជា: (ក) ត្រូវរៀបចំប្លង់កសាងទីស្នាក់ស្នូលឱ្យបានត្រឹមត្រូវ (ខ) ត្រូវផ្តល់ផ្ទះដល់កម្មករទៅតាមល័ក្ខខ័ណ្ឌ: (គ) ទីតាំងផ្ទះចាំបាច់ត្រូវស្ថិតនៅផុតពីកំពស់ទឹកជំនន់ ស្ថិតនៅឆ្ងាយពីទីកន្លែងដែលអាចផ្តល់ភាពកខ្វក់ និងកន្លែងដែលមានសត្វល្អិតច្រើន។ ផ្ទះត្រូវមានសំណាញ់ការពារមូស មានពន្លឺ និងចរន្តខ្យល់គ្រប់គ្រាន់ (ឃ) លក្ខណៈអនាម័យ: ផ្តល់ទឹកស្អាតឱ្យបានគ្រប់គ្រាន់ជាមួយនឹងមធ្យោបាយសំរាប់ដុសលាងនិងងូតទឹក សង់បង្គន់អនាម័យ និងកន្លែងសំរាម់ចោលកាកសំណល់រឹងត្រឹមត្រូវ និង (ង) ពិនិត្យអំពីលទ្ធភាពនៃការផ្តល់កន្លែងសំរាប់លំហែ (តារាងបាល់បោះ បាល់ទះ និងបាល់ទាត់) និងមណ្ឌលសុខភាព។ | ក្រុមហ៊ុន **តាន ហៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |
| | ហានិភ័យសុវត្ថិភាព | • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ការផ្តល់នូវការបណ្តុះបណ្តាលផ្សេងៗ និងការណែនាំដល់បុគ្គលិកកម្មករទាំងមុនពេលប្រគល់ភារកិច្ចផ្សេងៗ។ | **ក្រុមហ៊ុន តាន ហៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | - |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន** | | | | |
| ការដោះស្រាយបញ្ហាកម្មសិទ្ធិដី | លំនាំនៃការផ្លាស់ប្តូរកម្មសិទ្ធិដី | • ការដោះស្រាយបញ្ហាកម្មសិទ្ធិដីត្រូវមានលក្ខណៈគតិយុត្តិ ដោយផ្អែកទៅលើលទ្ធភាពបែងការប្រើប្រាស់ដី និងឬទិន្នផលដែលម្ចាស់ដីធ្លាប់ទទួលបានពីមុន ។ | | |
| **ផលប៉ះពាល់គុណភាពទឹក** | | | | |
| ការឈូសព្រៃដើម្បីដាំកៅស៊ូ | កកស្ទះដល់ការហូរដោះទឹកនៅក្នុងពេលដែលមានភ្លៀងធ្លាក់ខ្លាំង | • ក្រុមហ៊ុនបានឈូសព្រៃចំនួន៨១០០ហិកតា បាននឹងធ្វើអោយប៉ះពាល់ដល់គុណភាពទឹក តែផលប៉ះពាល់នេះមិនធ្ងន់ធ្ងរទេ ព្រោះក្រុមហ៊ុនរក្សាផ្ទៃដីព្រៃតំបន់ទ្រនាប់អូរ-ព្រែក ទៅតាមផែនការមេដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឯកភាព ដើម្បីការពារការហូរច្រោះដី ។ | ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ៤៥០ដុល្លា/ហិកតា |
| | ការជុះខ្យាច់និងភាពល្អក់កករបង្កដោយការឈូសព្រៃ | • ត្រូវរៀបចំច្បារដំណាំ ឬសួនច្បារបន្ថែម ទៅតាមប្លង់ Landscape Architecture លើផ្ទៃដីទំនេរមិនប្រើប្រាស់ ដើម្បីកាត់បន្ថយការហូរច្រោះពេលភ្លៀងខ្លាំង ។<br>• ស្តារគន្លងទឹកហូរដែលរាក់ ជាពិសេសនៅតាមមាត់លូឆងកាត់ផ្លូវ ដើម្បីរំដោះទឹកនៅតាមតំបន់ទំនាបដើម្បីកាត់បន្ថយនូវការកើតមាននូវទឹកជំនន់ភ្លាមៗ ពេលភ្លៀងខ្លាំង។ ម្យ៉ាងវិញទៀតការរំដោះទឹកនេះជាជំនួយដល់ការស្រូបយកនូវកករ បើមិនដូច្នោះទេវានឹងហូរធ្លាក់ចុះទៅផ្នែកខាងក្រោមរបស់ប្រព័ន្ធទឹកស្ទឹងជាមិនខាន ។<br>• ត្រូវដាក់លូបន្ថែមនៅតាមតំបន់ទំនាបណាដែលធំ ដើម្បីជួយរំដោះទឹកពីម្ខាងផ្លូវ អោយបានទាន់ពេលវេលា ។ | ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ៦.០០០ដុល្លា/ឆ្នាំ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃបាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់គុណភាពទឹក (ត)** | | | | |
| ការប្រើជីគីមី | ការប៉ះពាល់ដល់គុណភាពដី និងគុណភាពទឹក | • ហេតុប៉ះពាល់នេះអាចធ្វើការកាត់បន្ថយបានតាមរយៈការអនុវត្តន៍នូវវិធានការមួយចំនួន ដូចជា:<br>➢ ត្រូវប្រើប្រាស់ជីគីមី ឬថ្នាំសំលាប់សត្វល្អិត (ក្នុងករណីដែលមាន) ដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។<br>➢ ហាមប្រើដាច់ខាតចំពោះជីគីមីឬថ្នាំសំលាប់សត្វល្អិត ដែលរាជរដ្ឋាភិបាលកម្ពុជា បានហាមឃាត់ ។<br>➢ ត្រូវកាត់បន្ថយការប្រើប្រាស់ជីសរីរាង្គ ដែលធានាគុណភាពជំនួសឱ្យការប្រើប្រាស់ជីគីមី ឬថ្នាំ សំលាប់សត្វល្អិត ។ | | |
| ការឈូសព្រៃដើម្បីដាំកៅស៊ូ | ការច្រោះដី និងការដុះដី | • វិធានការណ៍មួយចំនួនដែលប្រើសម្រាប់កាត់បន្ថយហេតុប៉ះពាល់នេះមាន :<br>✓ រក្សាទុកផ្ទៃដីព្រៃតំបន់ទ្រនាប់អូរ-ព្រែក ទៅតាមផែនការបែងចែកការប្រើប្រាស់ដីទៅតាមផែនការមេដែលបានឯកភាពដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយ ។ ផ្ទៃដីព្រៃដែលរក្សាទុកដើម្បីការពារការហូរច្រោះនេះមានទំហំ៣.០៧១ហិកតា ។<br>✓ ក្រុមហ៊ុនបានដាំដំណាំរួមផ្សំ (Intercrops) នៅតាមចន្លោះរងកៅស៊ូ នៅក្នុងរយៈពេល០៣ឆ្នាំដំបូង រហូតដល់ពេលដើមឈើដាំទាំងនោះមានចុងមែកដុះស្ទើរជិត ។ | **ក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ជាក់ស្តែង |
| ការឈូសព្រៃដើម្បីដាំកៅស៊ូ | ការបាត់បង់ទីជម្រក និងហេតុប៉ះពាល់លើសត្វព្រៃ | • បិទផ្លាកនិងហាមឃាត់ ចំពោះបុគ្គលដែលគ្មានសិទ្ធិចូលទៅក្នុងតំបន់សម្បទាន ដើម្បីការពារជីវិតសត្វព្រៃពីការប្រមាញ់ ។<br>• ត្រូវអប់រំបុគ្គលិកកម្មកររបស់ក្រុមហ៊ុន ដើម្បីការពារនូវការប្រមូលអនុផលព្រៃឈើទាំងឡាយណា (ទាំងធនធានលើដី និងក្នុងទឹក) នៅក្នុងរូបភាពនៃការលក់ដូរ ។ | | |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់គុណភាពទឹក (ត)** | | | | |
| សម្លេង | ការរំខានដល់អារម្មណ៍ និងសោតវិញ្ញាណ | • គ្មានផលប៉ះពាល់ដែលបង្កឡើងដោយសម្លេង នៅក្នុងតំបន់នេះទេ ព្រោះសកម្មភាពឈូសឆាយព្រៃត្រូវបានបញ្ចប់ទាំងស្រុងហើយ ។ | **ក្រុមហ៊ុន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ជាក់ស្តែង |
| ការហៀរប្រេងឥន្ធនៈ ប្រេងរំអិល និងប្រេងខ្មៅចេញពីកន្លែងស្តុកប្រេង និងរោងម៉ាស៊ីនភ្លើង | ធ្វើឱ្យក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ | • ផលប៉ះពាល់នេះមានតិចតួចណាស់ស្ទើ តែមិនអាចគណនាបាន ។<br>• ទីតាំងស្នាក់របស់ ក្រុមហ៊ុននេះ ស្ថិតនៅលើទីទួលមិនលិចទឹក, បរិមាណប្រេងឥន្ធនៈដែលប្រើប្រាស់ប្រចាំថ្ងៃមានចំនួនតិចតួច ។<br>• ក្រុមការងារ មិនបានសង្កេតឃើញមានស្នាមចាក់ប្រេងខ្មៅនៅជុំវិញទីតាំងរោងម៉ាស៊ីនទេ ។ | | |
| ការបំភាយឧស្ម័នកាបូនិក និងសារធាតុបំពុលផ្សេងៗទៀតទៅក្នុងបរិយាកាស | ធ្វើឱ្យក្រខ្វក់ដល់បរិយាកាស | • ផលប៉ះពាល់នេះមានទំហំតូចស្ទើរតែមិនអាចគណនាបាន ។ ផលប៉ះពាល់ប្រភេទនេះជាផល ប៉ះពាល់បន្ទាប់បន្សំ ។ | | |
| ការចោលសំណល់រឹងផ្សេងៗទៅក្នុងមជ្ឈដ្ឋានជុំវិញ | ធ្វើឱ្យក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ | • ចោលកាកសំណល់រឹងទៅក្នុងរណ្តៅជាមួយនឹងការលុបដីជាប្រចាំ ។<br>• ប្រសិនបើអាច ចាំបាច់ត្រូវចោលសំរាមនៅក្រៅកន្លែងរស់នៅ តែប្រសិនបើមិនអាចត្រូវជ្រើសរើសកន្លែងណាមួយនៅក្នុងហើយរៀបចំឱ្យបានស្រួលបួល ជៀសវាងការបង្កឱ្យក្រខ្វក់ដល់<br>• ប្រភពទឹក ឬអណ្តូងទឹក ដែលធ្វើឱ្យបាត់បង់សោភ័ណភាព និងមានក្លិនស្អុយ ។ | ក្រុមហ៊ុន **តាន ហៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ជាក់ស្តែង |

Draft

២២៧. ថវិកាសរុបដែលគ្រោងសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងរយៈពេល ០៩ឆ្នាំនៃការអភិវឌ្ឍន៍ មានចំនួនសរុប **៣.០៨១.៥០០,០០** ដុល្លាអាមេរិក។ ថវិកានោះត្រូវប្រើសម្រាប់: (១) រៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ (២) គ្រប់គ្រងតំបន់ទ្រនាប់ (៣) ប្រាក់បរិច្ចាគ ដើម្បីអភិវឌ្ឍន៍សហគមន៍ និងស្តារបរិស្ថាន និង (៤) អនុវត្តន៍កម្មវិធីត្រួតពិនិត្យ និងវាយតម្លៃ។ ចំណែកឯថវិកាបំរុងសម្រាប់ការជួសជុលបរិស្ថាននៅក្នុងករណីចាំបាច់ផ្សេងៗ និងថវិកាបំរុងសម្រាប់ឧបត្ថម្ភសមាជិកគ្រួសារប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងបុគ្គលិកកម្មករ ដែលមានគ្រោះថ្នាក់ដោយចៃដន្យនៅក្នុងរយៈពេលនៃប្រតិបត្តិការ មិនបានដាក់បញ្ចូលទៅក្នុង តារាងតម្លៃប៉ាន់ស្មានសំរាប់ការអនុវត្តន៍ និងតាមដានពិនិត្យវាយតម្លៃនោះទេ។ ប៉ុន្តែ ក្រុមហ៊ុនត្រូវមានថវិកាបំរុង គ្រប់គ្រាន់សំរាប់គំរោងថវិកានេះ នៅក្នុងករណីនៃឧប្បទ្ទវហេតុដែលអាចកើតមានឡើងជាយថាហេតុ (សូមមើល តារាង ៦-២)។

**តារាង ៦-២: តម្លៃប៉ាន់ស្មានសម្រាប់ការអនុវត្តន៍ EMP និងការត្រួតពិនិត្យតាមដាន**

| កម្មវិធី | សកម្មភាព | ចំនួន | តម្លៃ (ដុល្លា) | |
|---|---|---|---|---|
| | | | ឯកតា | សរុប |
| ហេដ្ឋារចនាសម្ព័ន្ធ | រៀបចំគំរោង | ០១ | ១២០.០០០ | ១២០.០០០ |
| | ស្នាក់ការមេ និងកន្លែងបណ្តុះកូនកៅស៊ូ | ០១ | ១២០.០០០ | ១២០.០០០ |
| | ស្នាក់ការរង | ០៩ | ៤០.០០០ | ៣៦០.០០០ |
| | ប៉មយាមភ្លើង | ០៤ | ២.០០០ | ៨.០០០ |
| | ប៉ុស្តិ៍ល្បាត | ០៩ | ១.៥០០ | ១៣.៥០០ |
| | ប៉ុស្តិ៍សុវត្ថិភាព | ០២ | ២.៥០០ | ៥.០០០ |
| | មណ្ឌលសុខភាព | ០១ | ៦០.០០០ | ៦០.០០០ |
| | សាលារៀន | ០១ | ១២៥.០០០ | ១២៥.០០០ |
| | ប្រព័ន្ធផ្លូវ (គ.ម) | ៣៩៣ | ១.៨០០.០០០ | ១.៨០០.០០០ |
| | **សរុប** | | | **២.៦១១.៥០០** |
| គ្រប់គ្រងតំបន់ទ្រនាប់ | ស្ថានីយ៍ល្បាតអចិន្ត្រៃយ៍ | ០៣ | ៩០០ | ២.៧០០ |
| | អ្នកល្បាត (៧២ខែ) | ០២/ស្ថានីយ៍ | ១៥០ | ២១.៦០០ |
| | មធ្យោបាយ និងភស្តុភា | ០១/ស្ថានីយ៍ | ៥០០ | ១.៥០០ |
| | **សរុប** | | | **២៥.៨០០** |
| ប្រាក់បរិច្ចាគសង្គម និងបរិស្ថាន | ថវិកាបរិច្ចាគសម្រាប់អភិវឌ្ឍន៍សហគមន៍ | ០៦ឆ្នាំ | ២៥.០០០ | ១២៥.០០០ |
| | ថវិកាបរិច្ចាគសម្រាប់ស្តារបរិស្ថាន | ០៦ឆ្នាំ | ៣០.០០០ | ១៨០.០០០ |
| | **សរុប** | | | **៣០៥.០០០** |

Draft

| | | | | |
|---|---|---|---|---|
| | LEC (៧២ខែ) | ០១ | ៣០០ | ២១.៦០០ |
| ការត្រួតពិនិត្យ | ក្រសួងបរិស្ថាន (០៣នាក់) | ០៣ខែម្តង | ១.៥០០ | ៣៦.០០០ |
| | ក្រសួងបរិស្ថាន និងគណៈកម្មការអន្តរក្រសួង | ០៦ខែម្តង | ៥.០០០ | ៦០.០០០ |
| | តេស្ត៍ | ០៦ខែម្តង | ១.៨០០ | ២១.៦០០ |
| | | **សរុប** | | **១៣៩.២០០** |
| | | **សរុបរួម** | | **៣.០៨១.៩០០** |

**២២៨.** អ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator - LEC) នឹងត្រូវតាមដានត្រួតពិនិត្យនូវហេតុប៉ះពាល់ នឹងធ្វើរបាយការណ៍រៀងរាល់ខែ នៅក្នុងអាយុកាលនៃការប្រតិបត្តិគំរោង ដើម្បីធានាបានថាដំណើរប្រតិបត្តិនេះ បានអនុវត្តទៅតាមផែនការគ្រប់គ្រងបរិស្ថាន ដូចមានកំណត់នៅក្នុងតារាង៦-១។ ម្ចាស់គំរោងមិនត្រូវចាប់ផ្តើមដំណើរការគំរោងមុនពេលដែលក្រសួងបរិស្ថាន ផ្តល់ការអនុម័តជាផ្លូវការឡើយ។

**២២៩.** ការតាមដានត្រួតពិនិត្យវាយតំលៃគំរោង ត្រូវធ្វើទៅតាមតម្រូវការនៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ដូចបានសង្ខេបនៅក្នុងតារាង៦-៣។ ម្ចាស់គំរោងត្រូវធ្វើសវនកម្មផ្ទៃក្នុងរៀងរាល់១ខែម្តង ទៅលើការអនុវត្តន៍ EMP លើដំណើរការប្រតិបត្តិទាំងមូល ព្រមទាំងធ្វើរបាយការណ៍ត្រួតពិនិត្យបរិស្ថាន (Environmental Monitoring Report) រៀងរាល់ ០៦ខែម្តង មកក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងផ្តល់យោបល់។ ក្រសួងបរិស្ថាននឹងធ្វើការត្រួត ពិនិត្យ និងវាយតម្លៃទៅលើការអនុវត្តន៍ EMP រៀងរាល់ ០៣ខែម្តង។ ចំណែកឯគណៈកម្មការអន្តរក្រសួង ដែលដឹកនាំដោយក្រសួងបរិស្ថាន និងមានការចូលរួមពីសំណាក់មន្ត្រីសមត្ថកិច្ចមូលដ្ឋាន (ខេត្ត ស្រុក) នឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃរៀងរាល់ ០៦ខែម្តង។ ស្ថាប័នជំនាញក៏មានតួនាទីទទួលខុសត្រូវក្នុងការពិនិត្យលើនីតិវិធីប្តឹងតវ៉ា ដើម្បីធានាបានថា ការផ្តល់ប្រាក់ឧបត្ថម្ភ ចំពោះបុគ្គលិក/កម្មករដែលរងគ្រោះទទួលការដោះស្រាយបានត្រឹមត្រូវពីម្ចាស់ក្រុមហ៊ុន ឬមួយយ៉ាងណា ដើម្បីរាយការណ៍ទៅក្រសួងបរិស្ថាន។

**២៣០.** ម្ចាស់ក្រុមហ៊ុនត្រូវធ្វើការបណ្តុះបណ្តាលអំពីបទដ្ឋាននៃការគ្រប់គ្រងបរិស្ថាន គោលនយោបាយផែនការនិងនីតិវិធីនៃការអនុវត្តន៍និងការត្រួតពិនិត្យតាមដានដំណើរប្រតិបត្តិការគំរោងដល់បុគ្គលិករបស់ខ្លួន ឬក៏អ្នកម៉ៅការបន្ត។

អ្នកជំនាញបរិស្ថានត្រូវរៀបចំសៀវភៅប្រតិបត្តិការសង្ខេបដល់អ្នកសម្របសម្រួបបរិស្ថាននៅមូលដ្ឋាន ហើយត្រូវត្រួតពិនិត្យវាយតំលៃ និងផ្តល់នូវមតិយោបល់ផ្សេងៗដល់ម្ចាស់ក្រុមហ៊ុន ថាតើអ្នកបច្ចេកទេសបរិស្ថានរបស់ ក្រុមហ៊ុនគួរមានសមត្ថភាពកំរិតណាដើម្បីធានាបានដល់ការអនុវត្តន៍ និងការគ្រប់គ្រងការងារទាំងអស់នោះ។

**តារាង ៦-៣: សង្ខេបអំពីតំរូវការនៃការត្រួតពិនិត្យវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន-សង្គម**

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងសុវត្ថភាពការងារ និងសុខភាពបុគ្គលិកម្មករ** | | | | | | |
| • ប្រើទស្សនៈនៃការអភិវឌ្ឍន៍ជាប្រព័ន្ធ ដោយមានការបែងចែកផលធៀបប្រើប្រាស់ដីបានត្រឹមត្រូវ<br>• តំបន់ទ្រនាប់ប្រព័ន្ធផ្លូវទឹក សងខាងអូរ តំបន់ស្តារស្ថានព្រៃឡើងវិញ ដែលត្រូវកាត់ចេញដូចបញ្ជាក់នៅត្រង់ចំណុច ឧបសម្ព័ន្ធ ៣-១ របាយការណ៍ស្តីពី លទ្ធផលនៃការចុះសិក្សាទីតាំង ស្នើសុំដីសម្បទាន ។<br>• សហការជាមួយក្រុមការងារអន្តរក្រសួងរួមមាន : ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរមូលដ្ឋាន ធ្វើការត្រួតពិនិត្យ និងវាយតំលៃដង់ស៊ីតេឈើ និងមាឌឈើឈរទៅតាមការជាក់ស្តែង ដែលមាននៅក្នុងតំបន់គំរោងវិនិយោគ ដើម្បីបង់ចូលថវិការជាតិ ។<br>• ត្រូវរៀបចំផែនការមូលនិធិបរិស្ថាន ដើម្បីរៀបចំផែនការដាំដើមឈើឡើងវិញ នៅក្នុងតំបន់ដីសម្បទាន ។ | ការធ្វើគំរោង | ការិយាល័យ និងទីតាំងគំរោង | ផលធៀបប្រើប្រាស់ដី | ម្តងមុនពេលប្រតិបត្តិគំរោង | ក្រុមហ៊ុន **តាន យៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ជាក់ស្តែង |
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងសុវត្ថភាពការងារ និងសុខភាពបុគ្គលិកម្មករ (ត)** | | | | | | |
| • ស្វែងរក តាមដានលក្ខណៈគ្លីនិកអ្នកផ្ទុកជំងឺឱ្យបានទាន់ពេលវេលា<br>• ផ្តល់ការព្យាបាលឱ្យបានត្រឹមត្រូវនៅគ្រប់ករណីនៃការកើតមានទាំងអស់<br>• ធ្វើរបាយការណ៍អំពីការកើតមាន និងតាមដានអ្នកដែលប៉ះពាល់ជាមួយនឹងអ្នកជំងឺ<br>• ផ្តល់ការណែនាំអំពីការប្រើថ្នាំការពារជំងឺគ្រុនចាញ់ឱ្យបានត្រឹមត្រូវ | វិធីសាស្ត្រការពារជំងឺគ្រុនចាញ់ | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានា | ម្តងមុនពេលចាប់ផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន **តាន យៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់ |

| | | |
|---|---|---|
| • ជ្រលក់មុងជាមួយនឹងរបាយ Pyrathroid<br>• អនុវត្តន៍គំរោងកែលំអអនាម័យ ដើម្បីបំបាត់កន្លែងរស់នៅរបស់មូស និងផ្តល់ការអប់រំអំពីបញ្ហាសុខភាព និងការការពារជំងឺគ្រុនចាញ់<br>• ដាក់សំណាញ់តាមទ្វារ បង្អួចផ្ទះ និង<br>• ប្រើមុងជាប្រចាំ<br>• ស្លៀកពាក់ខោអាវដៃវែង និងប្រើថ្នាំការពារមូស<br>• តាមដានគ្លីនិក និងរោគសញ្ញារបស់ជំងឺ<br>• ធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាល ឱ្យបានទាន់ពេលវេលា និង<br>• ត្រួតពិនិត្យនូវឧប្បត្តិហេតុ និងកំណត់ទីកន្លែងកើតមានជំងឺ<br>• ត្រូវបំបែកអ្នកជំងឺឱ្យនៅកន្លែងផ្សេង និងផ្តល់ការព្យាបាលជាពិសេសទៅតាមប្រភេទប្រភេទនៃជំងឺ ។<br>• បាញ់ថ្នាំក្នុងបរិវេណរស់នៅចំងាយ២០០ម ដើម្បីសម្លាប់មូសពេញវ៉ៃយ ។<br>• ស្វែងរក និងបំផ្លាញទីតាំងជម្រកមូស ។<br>• ចាំបាច់ត្រូវប្រើថ្នាំសំលាប់ពងមូសចំពោះទីកន្លែងដែលមានមូសច្រើន ។<br>• អប់រំដល់បុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការគ្រប់គ្រងការរាគត្បាត ។ | ដែលរៀបចំឡើង | សរុបប្រមាណ<br>២៦០.០០០ដុល្លា<br>ក្នុងមួយឆ្នាំ<br>( ដែនការមេ) |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងសុវត្ថភាពការងារ និងសុខភាពបុគ្គលិកម្មករ (ត)** | | | | | | |
| • ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ ។<br>• ត្រួតពិនិត្យជាប្រចាំ អំពីគុណភាពរបស់ទឹក (វត្ថុមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក)<br>• ត្រូវធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។<br>• តាមដានរកប្រភពចំលង និងផ្តល់ការព្យាបាល ។<br>• ធានាឱ្យបាននូវសុវត្ថិភាព និងសម្អាតសំរាម និងការទុកដាក់នូវសំណល់រឹង នៅក្នុងផ្ទះដែលសង់សំរាប់កម្មករ ។<br>• កែលំអការសម្អាត បរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងទីកន្លែងរស់នៅ ដោយការសង់បង្គន់អនាម័យ និងកន្លែងសំរាប់ទុកដាក់សំណល់រឹង ។<br>• កែលំអអនាម័យបុគ្គល ជាពិសេសចំពោះអ្នករៀបចំអាហារ ។<br>• ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទីករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម ។<br>• រាយការណ៍នឹងធ្វើការត្រួតពិនិត្យអំពីឧប្បត្តិហេតុរបស់ជំងឺ ។ | វិធានការការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាត | ការិយាល័យ | មានការរៀបចំវិធីសាស្រ្តការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្រ្តនានាដែលរៀបចំឡើង | ម្តងមុនពេលចាប់ផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន **តាន យៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លាក្នុងមួយឆ្នាំ (ផែនការមេ) |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងសុវត្ថភាពការងារ និងសុខភាពបុគ្គលិកម្មករ (ត)**<br>• អប់រំបុគ្គលិក កម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀត ដូចជាការទប់ស្កាត់នូវទំនាក់ទំនងជាមួយអ្នកដែលធ្វើអាជីវកម្មលើផ្លូវភេទ ការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺឱ្យព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានបទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង។<br>• រាយការណ៍អំពីអ្នកជំងឺ ស្វែងរកអ្នកចំលង និងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាង អាជ្ញាធរសុខាភិបាល អាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។ | វិធានការ ការពារជំងឺផ្លូវភេទ | ការិយាល័យ | មានការរៀបចំវិធីសាស្រ្តការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្រ្តនានាដែលរៀបចំឡើង | ម្តងមុនពេលចាប់ផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ដែនការមេ) |

Draft

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងសុវត្ថភាពការងារ និងសុខភាពបុគ្គលិកម្មករ (ត)** | | | | | | |
| • ក្រុមហ៊ុនត្រូវរៀបចំប្លង់កសាងទីស្នាក់ស្នូលឱ្យបានត្រឹមត្រូវ<br>• ត្រូវផ្តល់ផ្ទះដល់កម្មករទៅតាមល័ក្ខខ័ណ្ឌៈ<br>• លក្ខណៈរូបៈ ទីតាំងផ្ទះ ចាំបាច់ត្រូវស្ងួតនៅផុតពីកំពស់ទឹកជំនន់ ស្ថិតនៅឆ្ងាយពីទីកន្លែងដែលអាចផ្តល់ភាពគ្រោះថ្នាក់ និងកន្លែងដែលមានសត្វល្អិតច្រើន។ ផ្ទះកម្មករត្រូវមានសំណាញ់ការពារមូស និងមានឆ្នាំការពារចោរ ហើយត្រូវមានពន្លឺគ្រប់គ្រាន់។ ម្យ៉ាងវិញទៀត ទីតាំងរបស់ផ្ទះ និងបន្ទប់ត្រូវមានចរន្តខ្យល់គ្រប់គ្រាន់ (ផ្ទៃបន្ទប់ ត្រូវបើកចំហយ៉ាងតិច១០ភាគរយ)។<br>• លក្ខណៈអនាម័យៈ ផ្តល់ទឹកស្អាតឱ្យបានគ្រប់គ្រាន់ ជាមួយនឹងមធ្យោបាយ សំរាប់ដុសលាង និងងូតទឹកសង់បង្គន់អនាម័យ និងកន្លែងសំរាប់ទុកដាក់សំណល់រឹងត្រឹមត្រូវ។<br>• ពិនិត្យអំពីលទ្ធភាពនៃការផ្តល់កន្លែងសំរាប់លំហែ (តារាងបាល់បោះ បាល់ទះ និងបាល់ទាត់) និងមណ្ឌលសុខភាព។ | មានសមាហរ័ណកម្មបរិស្ថាន និងសុខភាព | ការិយាល័យ | មានការរៀបចំត្រឹមត្រូវទៅតាមគោលការណ៍សមាហរ័ណកម្មបរិស្ថាន និងសុខភាព | ម្តងមុនចាប់ពេលផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |
| • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ការផ្តល់នូវការបណ្តុះបណ្តាលផ្សេងៗ និងការណែនាំដល់បុគ្គលិកកម្មករទាំងអស់មុនពេលប្រគល់ភារកិច្ចផ្សេងៗ។ | សុខភាពការងារ និងផែនការសុវត្ថិភាព | ការិយាល័យ | បុគ្គលិកទាំងអស់ទទួលបានការបណ្តុះបណ្តាលពេញលេញ | ម្តងមុនចាប់ពេលផ្តើម និង៣ខែម្តង ក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | - |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ផលប៉ះពាល់ពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន** | | | | | | |
| • ការដោះស្រាយបញ្ហាកម្មសិទ្ធិដីត្រូវមានលក្ខណៈគតិយុត្តិ ដោយផ្អែកទៅលើលទ្ធភាពនៃការប្រើប្រាស់ដី និងឫទ្ធិផលដែលម្ចាស់ដីធ្លាប់ទទួលបានពីមុន ។ | ម្ចាស់ដីពាក់ព័ន្ធបានទទួលការដោះស្រាយ | ទីវាល | ម្ចាស់ដីពាក់ព័ន្ធបានទទួលការដោះស្រាយ | ម្តងមុនពេលអនុវត្តន៍គំរោង | ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | តាមជាក់ស្តែង |
| **ផលប៉ះពាល់គុណភាពទឹក ក្នុងការឈូសឆាយព្រៃដើម្បីដាំកៅស៊ូ** | | | | | | |
| • ក្រុមហ៊ុនបានឈូសព្រៃចំនួន៨១០០ហិកតា បាននឹងធ្វើអោយប៉ះពាល់ដល់គុណភាពទឹក តែ ផលប៉ះពាល់នេះមិនធ្ងន់ធ្ងរទេ ព្រោះក្រុមហ៊ុនរក្សាផ្ទៃដីព្រៃតំបន់ទ្រនាប់អូរ-ព្រែក ទៅតាមផែនការមេ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឯកភាពដើម្បីការពារការហូរច្រោះដី ។ | ការច្រោះដី និងការដុះដី | ទីវាល | ការច្រោះដី និងការដុះដី | ០៣ខែម្តង | - ក្រសួងបរិស្ថាន<br>- ក្រុមការងារអន្តរក្រសួង<br>- ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | ៤៥០ដុល្លា/ហិកតា |
| • រៀបចំច្បារដំណាំ ឬសួនច្បារបន្ថែម ទៅតាមប្លង់ Landscape Architecture លើផ្ទៃដីទំនេរ មិនប្រើប្រាស់ ដើម្បីកាត់បន្ថយការហូរច្រោះពេលភ្លៀងខ្លាំង ។<br>• ស្តារគន្លងទឹកហូរដែលរាក់ ជាពិសេសនៅតាមមាត់លូឆងកាត់ផ្លូវ ដើម្បីរំដោះទឹកនៅតាមតំបន់ ទំនាបដើម្បីកាត់បន្ថយនូវការកើតមាននូវទឹកជំនន់ភ្លាមៗ ពេលភ្លៀងខ្លាំង ។ ម្យ៉ាងវិញទៀតការ រំដោះទឹកនេះជាជំនួយដល់ការស្រូបយកនូវកករ បើមិនដូច្នោះទេវានឹងហូរធ្លាក់ចុះទៅផ្នែកខាង ក្រោមរបស់ប្រព័ន្ធទឹកស្ទឹងជាមិនខាន ។<br>• ដាក់លូបន្ថែមនៅតាមតំបន់ទំនាបណាដែលធំ ដើម្បីជួយរំដោះទឹកពីម្ខាងផ្លូវ | ការច្រោះដី និងការដុះដីខ្សាច់ | ទីវាល | ការច្រោះដី និងការដុះដី | ០៣ខែម្តង | - ក្រសួងបរិស្ថាន<br>- ក្រុមការងារអន្តរក្រសួង<br>- ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | ៦.០០០ ដុល្លា/ឆ្នាំ |

| | | | | | | |
|---|---|---|---|---|---|---|
| អោយបានទាន់ ពេលវេលា ។ | | | | | | |
| **ផលប៉ះពាល់គុណភាពទឹក (ត)**<br>• ត្រូវប្រើប្រាស់ជីគីមី ឬថ្នាំសំលាប់សត្វល្អិត (ក្នុងករណីដែលមាន) ដែលកំណត់ដោយ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។<br>• ហាមប្រើដាច់ខាតចំពោះជីគីមីឬថ្នាំសំលាប់សត្វល្អិត ដែលរាជរដ្ឋាភិបាលកម្ពុជាបានហាមឃាត់ ។<br>• ត្រូវកាត់បន្ថយការប្រើប្រាស់ជីសរីរាង្គ ដែលធានាគុណភាពជំនួសឱ្យការប្រើប្រាស់ជីគីមី ឬថ្នាំ សំលាប់សត្វល្អិត ។ | ជាតិគីមីនៅ ក្នុងដី និងទឹក | ទីវាល | បង្កការខូចគុណភាពដី និងទឹកក្នុងមជ្ឈដ្ឋានជុំវិញ ដោយការប្រើប្រាស់ | បីខែម្តង | ស្ថាប័នជំនាញ | - |
| • រក្សាទុកផ្ទៃដីព្រៃតំបន់ទ្រនាប់អូរ-ព្រែក ទៅតាមផែនការបែងចែកការប្រើប្រាស់ដី ទៅតាមផែនការមេដែលបានឯកភាពដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ផ្ទៃដី ព្រៃដែលរក្សាទុកដើម្បីការពារការហូរច្រោះនេះមានទំហំ ៣.០៧១ហិកតា ។<br>• ក្រុមហ៊ុនបានដាំដំណាំរួមផ្សំ (Intercrops) នៅតាមចន្លោះរងកៅស៊ូ នៅក្នុងរយៈពេល០៣ឆ្នាំដំបូងរហូតដល់ពេលដើមឈើដាំទាំងនោះមានចុងមែកដុះស្ទើរជិត ។ | ការច្រោះដី និងការដុះដី | ទីវាល | ការច្រោះដី និងការដុះដី | ០៣ខែម្តង | - ក្រសួងបរិស្ថាន<br>- ក្រុមការងារ អន្តរក្រសួង<br>- ក្រុមហ៊ុន **តាន ឃៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | ជាក់ស្តែង |
| • បិទផ្លាកនិងហាមឃាត់ ចំពោះបុគ្គលដែលគ្មានសិទ្ធិចូលទៅក្នុងតំបន់សម្បទាន ដើម្បីការពារជីវិត សត្វព្រៃពីការប្រមាញ់ ។<br>• ត្រូវអប់រំបុគ្គលិកកម្មកររបស់ក្រុមហ៊ុន ដើម្បីការពារនូវការប្រមូលអនុផលព្រៃឈើទាំងឡាយណា (ទាំងធនធានលើដី និងក្នុងទឹក) នៅក្នុងរូបភាពនៃការលក់ដូរ ។ | បាត់បង់ទីជំរក និង ប៉ះពាល់ដល់សត្វព្រៃ | ទីវាល | តំបន់ទ្រនាប់ ត្រូវបាន រក្សាទុកត្រឹមត្រូវ តាមផែនការបែងចែក ការប្រើប្រាស់ដី | ០៣ខែម្តង | - ក្រសួងបរិស្ថាន<br>- ក្រុមការងារ អន្តរក្រសួង<br>- ក្រុមហ៊ុន **តាន ឃៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | ជាក់ស្តែង |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ផលប៉ះពាល់គុណភាពទឹក (ត)** | | | | | | |
| • គ្មានផលប៉ះពាល់ដែលបង្កឡើងដោយសម្លេង នៅក្នុងតំបន់នេះទេ ព្រោះសកម្មភាពឈូសឆាយព្រៃត្រូវបានបញ្ចប់ទាំងស្រុងហើយ ។ | សកម្មភាពគ្រឿងចក្រ | ទីវាល | បង្កការរំខានដល់អារម្មណ៍ ប្រព័ន្ធសោតវិញ្ញាណ និងប្រព័ន្ធដកដង្ហើម និងការលូតលាស់របស់រុក្ខជាតិ | ០៣ខែម្តង | - ក្រសួងបរិស្ថាន<br>- ក្រុមការងារអន្តរក្រសួង<br>- ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** | ជាក់ស្តែង |
| • ផលប៉ះពាល់នេះមានតិចតួចណាស់ស្ទើ តែមិនអាចគណនាបាន ។<br>• ទីតាំងស្នាក់របស់ ក្រុមហ៊ុននេះ ស្ថិតនៅលើទីទួលមិនលិចទឹក, បរិមាណប្រេង ឥន្ធនៈដែលប្រើប្រាស់ ប្រចាំថ្ងៃមានចំនួនតិចតួច ។<br>• ក្រុមការងារមិនបានសង្កេតឃើញមានស្នាមចាក់ប្រេងខ្មៅនៅជុំវិញទីតាំងរោងម៉ាស៊ីនទេ ។ | ផែនការសាងសង់ | ទីវាល | បង្កការក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ដោយការលើកដីរៀបចំទីតាំងចតគ្រឿងចក្រ | ០៣ខែម្តង | ស្ថាប័នជំនាញ<br>- ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស** | ជាក់ស្តែង |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ផលប៉ះពាល់គុណភាពទឹក ( ត)** | | | | | | |
| • ផលប៉ះពាល់នេះមានទំហំតូចស្ទើរតែមិនអាចគណនាបាន ។<br>ផលប៉ះពាល់ប្រភេទនេះជាផល ប៉ះពាល់ បន្ទាប់បន្សំ ។ | ការបំភាយឧស្ម័នកាបូនិក និងសារធាតុពុលក្នុងបរយាកាស | ទីវាល | ការធ្វើឱ្យក្រខ្វក់ដល់បរិយាកាស | ០៣ខែម្តង | - ក្រសួងបរិស្ថាន<br>- ក្រុមការងារអន្តរក្រសួង<br>- ក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ | ជាក់ស្តែង |
| • ចោលកាកសំណល់រឹងទៅក្នុងរណ្តៅជាមួយនឹងការលុបដីជាប្រចាំ ។<br>• ប្រសិនបើអាច ចាំបាច់ត្រូវចោលសំរាមនៅក្រៅកន្លែងរស់នៅ តែប្រសិនបើមិនអាចត្រូវ ជ្រើសរើសកន្លែងណាមួយនៅក្នុងហើយរៀបចំឱ្យបានស្រួលបួល ជៀសវាងការបង្កឱ្យក្រខ្វក់ដល់ ។ | ធ្វើឱ្យកខ្វក់ដល់មជ្ឈដ្ឋានជុំវិញ | ទីវាល | សោភ័ណភាពមជ្ឈដ្ឋានជុំវិញ | ០៣ខែម្តង | - ក្រសួងបរិស្ថាន<br>- ក្រុមការងារអន្តរក្រសួង<br>- ក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ | ជាក់ស្តែង |

Draft

**២៣១.** ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONGTHOM APHIVATH CAOUTCHOUC CO., LTD.)** មានផែនការអភិវឌ្ឍន៍មូលដ្ឋាន ដូចបានជំរាបជូនខាងលើ មានបញ្ជាក់លំអិតនៅក្នុងតារាង ៦-៤ ខាងក្រោម ។

**តារាង ៦-៤: ផែនការចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋានរបស់ក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ**

| កម្មវិធី | សកម្មភាពដែលត្រូវអនុវត្ត | គំរោងផ្តល់ជូនក្នុងមួយឆ្នាំ | | |
|---|---|---|---|---|
| | | ចំនួន | ឯកតា | សរុប |
| ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ | ផ្តល់អណ្តូងទឹកស្អាត (០១/០៥គ្រួសារ) | ១០ | ១.៥០០ | ១៥.០០០ |
| | ជួសជុល និងសាងសង់ផ្លូវលំជនបទក្នុងតំបន់គំរោង (ម) | ១.០០០ | ១០ | ១០.០០០ |
| | កសាង និងជួសជុលសាលារៀន (ក្នុងទីតាំងក្រុមហ៊ុន) | ០១ | ១២៥.០០០ | ១២៥.០០០ |
| | មណ្ឌលសុខភាព របស់ក្រុមហ៊ុន (០១ក្នុងតំបន់សម្បទាន) | ០១ | ៦០.០០០ | ៦០.០០០ |
| | ជីកស្រះចិញ្ចឹមត្រី (២០ម x៤០ម ៣,៥ម=២,៤០០ម៣) | ៣០ | ៣០០០ | ៩០.០០០ |
| | ភ្តល់ពូជមាន់ និងជ្រូក( ចំនួនគ្រួសារ) | ១៦០ | ៣០ | ៤.៨០០ |
| | សាងសង់ប្រព័ន្ធធារាសាស្ត្រ (ប្រាក់បរិច្ចាគសង្គម) | ដកប្រាក់ពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម | | |

Draft